002/19-09-2007-ECCC/TC
E1/138

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 12 / 2012
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ពុធ ទី ២៤ ខែ តុលា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១២៥

រៀបចំដោយ: សែ កុលវុឌ្ឍី និង Roger PHILLIPS

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក ឌុច ផារី, លោក Roger PHILLIPS. |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ចាន់ តារាស្មី, លោក វេង ហ៊ាត់, លោក Tarik ABDULHAK, លោក Vincent DE WILDE D'ESTMAEL. |
| ជនជាប់ចោទ៖ នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Jasper PAUW. |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael G. KARNAVAS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោកស្រី ម៉ុច សុវណ្ណារី, លោកស្រី ជេត វណ្ណលី, លោក វ៉ែន ពៅ, លោកស្រី BEINI Ye, លោកស្រី Lyma NGUYEN. |
| សាក្សី/ដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ឡាយ បូនី (TCCP-64), លោកស្រី គង់ គីម ហៅកែ (TCW-362) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី ស្វ សុឡារី |
| ផ្សេងៗ៖ កញ្ញា Sonia MESSAOUDI, លោក លីម ប៊ុនហេង (មេធាវីប្រឹក្សាសាក្សី គង់ គីម) |

**<u>ពេលវេលាទូទៅរបស់តុលាការ៖</u>**

| | | |
|---|---|---|
| ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ០៩.០០ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤០ | បញ្ចប់ម៉ោង៖ ១១.០៥ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.២០ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ៥ ម៉ោង និង ១០ នាទី | | |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ | មេធាវីការពារក្តី អៀង សារី | ០៩.០៣<br>១៣.៣៩ | ០៩.០៤<br>១៣.៤១ |
| | មេធាវីការពារក្តី នួន ជា | ១២.១៧ | ១២.១៨ |
| អវត្តមានមេធាវីអន្តរជាតិការពារក្តី លោក ខៀវ សំផន | ក្រឡាបញ្ជី | ០៩.០៤ | ០៩.០៥ |
| ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី (TCCP-64) | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ៩.០៦ | ០៩.៥៨ |
| | សហព្រះរាជអាជ្ញា | ០៩.៥៨ | ១០.៣៦ |
| | មេធាវីការពារក្តី នួន ជា | ១១.០៤ | ១១.៥៥ |

| | | | |
|---|---|---|---|
| | ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី | ១១.៥៨ | ១២.១៥ |
| សំណើសុំរបស់មេធាវីការពារក្តី អៀង សារី អំពីវិសាលភាពនៃការបង្ហាញអំពីទុក្ខសោក ឬ ព្យសនកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី | មេធាវីការពារក្តី អៀង សារី | ១៣.៣៤ | ១៣.៣៩ |
| ការតាំងសំណួរទៅសាក្សី គង់ គីម ហៅកី (TCW-362) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១៣.៤៣<br>១៣.៥០ | ១៣.៤៩<br>១៦.០៣ |
| អវត្តមានរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សវនាការថ្ងៃបន្ទាប់ | មេធាវីនាំមុខ | ១៦.០៤ | ១៦.០៤ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ</u>**

ជនជាប់ចោទ អៀង សារី (E237) បានលះបង់សិទ្ធិក្នុងការចូលរួមសវនាការសម្រាប់រយៈពេលពេញមួយថ្ងៃ ដោយមូលហេតុសុខភាព។ អង្គជំនុំជម្រះសម្រេចបន្ត សវនាការដោយអវត្តមានជនជាប់ចោទ អៀង សារី ផ្អែកតាមរបាយការណ៍ពេទ្យដែលបង្ហាញថា លោក អៀង សារី ត្រូវបន្តសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលគាត់បានលះបង់សិទ្ធិក្នុងការស្តាប់សក្ខីកម្ម សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០រូប។

ជនជាប់ចោទ នួន ជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ ពីបន្ទប់សវនាការសម្រាប់សវនាការពេលរសៀល។ អង្គជំនុំជម្រះសម្រេចតាមការស្នើសុំ។

**<u>អវត្តមានមេធាវីអន្តរជាតិការពារក្តី លោក ខៀវ សំផន</u>**

ក្រឡាបញ្ជីបានរាយការណ៍ថា មេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន គឺលោកមេធាវី VERCKEN អវត្តមានដោយមូលហេតុផ្ទាល់ខ្លួន។

**<u>ការបន្តតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី (TCCP-64)</u>**

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបន្តការតាំងសំណួរនិងបញ្ចប់ការតាំងសំណួរទៅដើមបណ្តឹងរដ្ឋប្ប

វេណី ឡាយ បូនី បន្ទាប់មក មេធាវីការពារក្តី នួន ជា បានតាំងសំណួរ។ មេធាវីការពារក្តី អៀង សារី និង ខៀវ សំផន មិនមានសំណួរសួរទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះទេ ជាចុងក្រោយដើមបណ្តឹងរដ្ឋប្បវេណីបាន ធ្វើសេចក្តីថ្លែងអំពីទុក្ខសោក និងព្យសនកម្មដែលគាត់បានទទួលរងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។

**ការកត់សម្គាល់អំពីការថ្លែងទុកសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី**

មេធាវីការពារក្តី អៀង សារី បានស្នើសុំឱ្យអង្គជំនុំជម្រះបញ្ជាក់ថា តើសេចក្តីថ្លែងទុកសោករបស់ដើមបណ្តឹង ដែលហួសពីវិសាលភាពនៃការជំនុំជម្រះនៅពេលនេះ ត្រូវបានអង្គជំនុំជម្រះយកមកពិចារណាជាភស្តុតាង ដែលឬទេ។

អង្គជំនុំជម្រះនឹងពិនិត្យពិចារណាសម្រេចនៅពេលដែលអង្គជំនុំជម្រះទទួលបានពាក្យសុំជាក់លាក់ពី មេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅលើបញ្ហានេះ។ ភាគីទាំងអស់មិនអនុញ្ញាតិឱ្យធ្វើសេចក្តីសន្និដ្ឋាន អំពីបញ្ហា នេះទេ។ ទោះបីជាយ៉ាងណាក៏ដោយ ទាក់ទងនឹងទម្ងន់នៃភស្តុតាង អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះ នឹងពិចារណាអំពីអង្គហេតុដែលបានលើកឡើងក្នុងអំឡុងពេលដេញដោលនេះ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន។

**ការតាំងសំណួរទៅ សាក្សី គង់ គីម ហៅគី** (TCW-362)

ប្រធានអង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួនទាក់ទងនឹងប្រវត្តិសាវតារបស់សាក្សី និងសិទ្ធិករណីកិច្ច របស់សាក្សី។ បន្ទាប់មកសហព្រះរាជអាជ្ញាបានចាប់ផ្តើមតាំងសំណួរទៅសាក្សី គង់ គីម។

**អវត្តមានរបស់មេធាវីនាំមុខសម្រាប់សវនាការថ្ងៃបន្ទាប់**

មេធាវីនាំមុខ ពេជ្រ អង្គ បានជូនដំណឹងមកអង្គជំនុំជម្រះថា ខ្លួននឹងអវត្តមាននៅសវនាការថ្ងៃស្អែក។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/3958 | D246/3 | 00373243-00373256 00379154-00379165 00422445-00422458 | កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី LAY Bony ឡាយ បូនី Written Record of Interview of Civil Party LAY Bony ឡាយ បូនី Procès verbal d'audition de partie civile Mme LAY Bony ឡាយ បូនី | P | 00373249-50, 00373255-56 | 00379159-60, 00379164 | 00422451-452, 00422457-58 |
| E3/3959 | D166/74 | 00270162-00270170 00278680-00278687 00486095-00486101 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ គីម KUNG Kim Written Record of Interview of KUNG Kim Procès verbal d'audition de KUNG Kim | P | 00270163-65, 00270165-66 | 00278681-83, 00278683-84 | 00486096-97, 00486098 |
| E3/3960 | 19.96 | 00054815-00054873 00184120-00184124, 00633857-00633907 00403335-00403382 | បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឡេង គីម ហៅ គង់ គីម អាយុ ៥៦ឆ្នាំ, សរសេរជាភាសាខ្មែរ សម្ភាសន៍ដោយ អ៊ីសា ឧស្មាន, វ៉ាន់ថាន់ ពៅដារ៉ា និង ផាន់ សុផា នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០២ DC-Cam Statement of LENG Kim alias Kung Kim. DC-Cam Statement of LENG Kim alias Kung Kim. | P | 00054834-36, 00054839-40, 00054856, 00054850, 00054843-44 | 00633874-75, 00633878-79, 00633892, 00633887, 00633881-82 | 00403350-51, 00403354-55, 00403369, 00403363, 00403357-58 |
| E3/1891 | 5.89 | 00017526-00017945 00828043-00828064, 00096817-00096834 00788257-00788289 | ចម្លើយសារភាពរបស់ស្បូវហ៊ឹម ហៅអឿនជាភាសាខ្មែរនៅថ្ងៃទី១៧កុម្ភៈ១៩៧៧ English summary of S-21 Confession of SBAUV Him alias Euan [Partial T.] Aveux de SBAUV Him alias EUAN ou Oeun à S-21 | P | | | |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា (១២.១៨) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការសម្រាប់ពេលរសៀល និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ឃុំខ្លួននៅក្រោមសាលសវនាការ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។

00867335



- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី (TCCP-64) ត្រឡប់ទៅកាន់គេហដ្ឋានរបស់គាត់វិញ។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញជូនសាក្សី គង់ គីម (TCW-362) ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងឱ្យនាំគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញ នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១២។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩.00 ព្រឹក ថ្ងៃព្រហស្បត្តិ៍ ទី ២៥ ខែ តុលា ឆ្នាំ ២០១២។

| <u>**កាលបរិច្ឆេទបន្តសវនាការ៖**</u> |
| --- |
| សវនាការនឹងបន្តនៅថ្ងៃព្រហស្បត្តិ៍ ទី ២៥ ខែ តុលា ឆ្នាំ ២០១២ វេលាម៉ោង ០៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុណ[illegible] Roger PHILLIPS